# ការសំភាសន៍របស់អ្នកមីង ផេង យ៉ម

កៈ អ្នកធ្វើការសំភាសន៍ គីម ម៉េង ខៈ អ្នកដែលត្រូវបានគេសំភាសន៍ ផេង យ៉ម

## ការសង្ខេបរបស់អ្នកមីង ផេង យ៉ម

អ្នកមីង ផេង យ៉ម គាត់មានអាយុ ៥៦ឆ្នាំ ក្នុងឆ្នាំ ២០១៨ អ្នកមីង ផេង យ៉ម ភេទ ស្រី

អ្នកមីង ផេង យ៉ម មានកូនចំនួន ៨ នាក់ អ្នកមីង ផេង យ៉ម ភូមិ ឧញ៉្ញាតី កោះ ឧកញ៉្ញាតី ខេត្ត កណ្ដាល អ្នកមីង ផេង យ៉ម ភូមិ មានទីលំនៅនាពេលបច្ចុប្បន្ននៅ ភូមិ ឧកញ៉្ញាតី កោះ ឧកញ៉្ញាតី ខេត្ត កណ្ដាល។

កៈ
ចឹងជាដំបូងជំរាសួរលោកយាយខ្ញុំបាទមកពីរខាងសាកលវិទ្យាល័យបីបាយយូនៃសហរដ្ឋអាមេរិចហើយមានការអញ្ជើញដើម្បីមានការសំភាសន៍អ្នកមីងអំពីរពង្សប្រវត្តិតតើអ្នកមីងអាយអនុញ្ញាត្តិអោយខ្ញុំបានសំភាសន៍អ្នកមីងពង្សប្រវត្តិអ្នកមីងបានដែលឬទេអ្នកមីង???

ខៈ ចាសបាន ៕

កៈ ចឹងថ្ងៃនេះគឺជាថ្ងៃដែលខ្ញុំបានសំភាសន៍អ្នកមីងគឺជាថ្ងៃទី០២ ខែ ០៦ ( មិថុនា ) ឆ្នាំ២០១៨ហើយធ្វើការសំភាសន៍ដោយរូបខ្ញុំបាទឈ្មោះគីមម៉េងហើយនាក់សំភាសន៍អ្នកមីងឈ្មោះ ផេង យ៉ម
ចឹងផ្ដើមឈ្មោះដំបូងខ្ញុំអាចស្គាល់ឈ្មោះពេញរបស់អ្នកមីងបានដែលទេអ្នកមីង???

ខៈ ចាសសំរាប់ត្រកូលរបស់ខ្ញុំនឹងគឺខ្ញុំមានឈ្មោះថា ផេហ យ៉ម នឹងតែម្ដងចាស៕

កៈ បាទហើយចឹងសំរាប់ឆ្នាំនឹងថាតើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយទៅអ្នកមីង???

ខៈចាសសំរាប់ឆ្នាំនឹងគឺខ្ញុំមានអាយុ ៥៦ ឆ្នាំហើយចាស៕

កៈ បាទហើយសំរាប់អ្នកមីងមានទីកន្លែងកំណើតនឹងនៅទីកន្លែងណាដែលទៅអ្នកមីង???

ខៈ
ចាសសំរាប់ស្រុកកំណើតរបស់ខ្ញុំនឹងគឺនៅស្រុកកំណើតកើតតែម្ដងមែនដែលទេចាសសំរាប់ស្រុកកំណើតរបស់ខ្ញុំនឹងគឺនៅឃុំបាដោលហើយនឹងគឺជាស្រុកកំណើតរបស់ខ្ញុំនឹងហាសហើយសំរាប់ស្រុកកំណើតរបស់ប្ដីរបស់ខ្ញុំនឹងហើយសំរាប់ស្រុកកំណើតរបស់ខ្ញុំនឹងគឺនៅស្រុកបាដោលខេត្តកណ្ដាលហាសចាស៕

កៈ បាទហើយចឹងសំរាប់អ្នកមីងមានកូនចំនួនប៉ុន្មាននាក់ដែលអ្នកមីង???

ខៈ ចាសសំរាប់ខ្ញុំគឺខ្ញុំមានកូនចំនួនមើលចង់ភ្លេចកូនហើយកូនរបស់ខ្ញុំនឹងគឺមាន ៨នាក់ហាសចាសនិយាយទៅគ្រាន់ថាចេះសំរាប់ប្ដីរបស់ខ្ញុំនឹងគឺគាត់មានប្រពន្ធមុនចឹងហាសដល់ពេលដែលប្រពន្ធរបស់គាត់នឹងបានស្លាប់ហើយបានគាត់នឹងបានមកយកខ្ញុំនឹងបូកទាំងកូនមុនហើយនឹងក្រោយនឹងទាំងអស់ ៨នាក់
ចាសហើយសំរាប់កូនផ្ទាល់របស់ខ្ញុំនឹងគឺមានតែ ៤ នាក់
នោះទេចាសហើយសំរាប់កូនផ្ទាល់របស់ខ្ញុំនឹងគឺមាន ស្រីនឹង ៣នាក់ ហើយនឹងប្រុស ចំនួន ១ នាក់នឹងគឺជាកូនផ្ទាល់របស់ខ្ញុំនឹងហាសចាស៕

កៈ បាទហើយចឹងបានន័យថាអ្នកមីងមានកូន ៨ នាក់មានបានចាំកូនរបស់អ្នកមីងទាំង ៨ នាក់ដែលរឺទេអ្នកមីង???

ខៈ ចាសសំរាប់កូនរបស់ខ្ញុំទាំង ៨ នាក់នឹងគឺខ្ញុំបានចាំ ៕

កៈ បាទហើយចឹងសំរាប់អ្នកមីងអាចរាប់ហើយនឹងប្រាប់ឈ្មោះកូនរបស់អ្នកមីងទាំង ៨ នាក់ម្ដងម្នាក់ម្ដងម្នាក់បានដែលរឺទេអ្នកមីងទី១គាត់មានឈ្មោះអ្វីដែលទៅអ្នកមីង???

ខៈ
និយាយទៅទាំងនាមត្រកូលតែម្ដងមែនដែលទេចាសសំរាប់កូនទី១របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ហុង ផាន ហើយសំរាប់កូនទី២របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ហុង ផេង
ហើយសំរាប់កូនទី៣របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ហុង ថន
ហើយសំរាប់កូនទី៤របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ហុង ផាង
ហើយសំរាប់កូនទី៥របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ហុង យៀក
ហើយសំរាប់កូនទី៦របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ហុង ប៉ែល
ហើយសំរាប់កូនទី៧របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ហុង រ៉ែត
ហើយសំរាប់កូនទី៨របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា សីហា ចាស៕

កៈ Wow ចឹងសំរាប់អ្នកមីងមានកូនចំនួន ៨នាក់ ហើយចឹងសំរាប់សព្វថ្ងៃនឹងកូនរបស់ទាំង ៨នាក់នឹងថាតើគាត់រស់នៅជាមួយនឹងអ្នកមីងរឺក៏រស់នៅផ្សេងគ្នាដែលទៅអ្នកមីង???

ខៈ
ចាសសំរាប់កូនរបស់ខ្ញុំនឹងខ្លះនឹងគឺគេបានរស់នៅផ្សេងគ្នាដោយសារគេមានគ្រួសារអស់ហើយខ្លះចឹងហាសចាសហើយសំរាប់នៅតែឪពុកនឹងគឺដូចថានៅកូនស្រីដែលមីងពៅនឹងហើយនឹងអាកូនកំលោះរបស់ខ្ញុំនឹងមួយនឹងហាសចាស៕

កៈ បាទហើយចឹងសំរាប់ពួកគាត់មានគ្រួសារអស់ហើយមែនដែលទេអ្នកមីង???

ខៈ ចាសពួកគាត់មានគ្រួសារអស់ហើយចាស៕

កៈ
បាទហើយចឹងសំរាប់សព្វថ្ងៃនឹងថាតើពូកគាត់នៅធ្វើការងាររឺក៏យ៉ាងមិចដែលទៅអ្នកមីង???

ខៈ
ចាសសំរាប់កូនដែលមានគ្រួសារមែនដែលទេចាសសំរាប់កូនដែលមានគ្រួសារនឹងគឺគេសុទ្ធតែមុខរបបអស់ហើយចឹងហាសចាសមួយនឹងគឺធ្វើការងារនៅអូរ៉ាល់នឹងសំរាប់កូនច្បងគេហាសហើយសំរាប់កូនពៅរបស់ខ្ញុំនឹងគឺគេបានទៅធ្វើខាងទឹកសុទ្ធអូរ៉ោលនឹងដែលហាសចាសហើយសំរាប់ប្ដីហើយនឹងកូនប្រសាររបស់ខ្ញុំនឹងគឺគាត់បានធ្វើការងារខាទឹកសុទ្ធខាងអូរ៉ោលនឹងដែលចាសហើយសំរាប់អ្នកផ្សេងនឹងគឺគេបានធ្វើស្រែហើយនឹងចំការរបស់ចឹងហាសចាស៕

កៈ
បាទហើយចឹងអរគុណច្រើនហើយចឹងសំរាប់ប្ដីរបស់អ្នកមីងគាត់មានឈ្មោះអ្វីដែលទៅអ្នកមីង???

ខៈ ចាសសំរាប់ប្ដីរបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា សេក សន ៕

កៈ បាទហើយសំរាប់ប្ដីរបស់អ្នកមីងគាត់មានអាយុប៉ុន្មានឆ្នាំហើយទៅអ្នកមីង???

ខៈ
ចាសសំរាប់ប្ដីរបស់ខ្ញុំនឹងគឺគាត់បានស្លាប់ហើយចឹងហាសហើយនិយាយទៅគឺគាត់បានស្លាប់នឹងអស់រយះពេល ១៣ឆ្នាំហើយចាស៕

កៈ
បាទហើយចឹងប្រសិនជាយើងគិតទាំងអាយុស្លាប់របស់គាត់នឹងប្រហែលជាគាត់មានអាយុប៉ុន្មានឆ្នាំហើយទៅអ្នកមីង???

ខៈ ចាសប្រសិនជាយើងគិតទៅប្រហែលជាគាត់នឹងអាយុ ៥៨ ឆ្នាំ រឺក៏ ៥៩ ឆ្នាំហើយចាស៕

កៈ បាទហើយចឹងសំរាប់ប្ដីរបស់អ្នកមីងគាត់នឹងអាយុ ៥៨ ឆ្នាំ រឺក៏ ៥៩ ឆ្នាំ
ចឹងបានន័យថាគាត់បងរបស់អ្នកមីងមែនដែលទេអ្នកមីង???

ខៈ ចាសសំរាប់ប្ដីរបស់ខ្ញុំនឹងគឺគាត់បងខ្ញុំតាចាស៕

កៈ
បាទហើយចឹងសំរាប់អ្នកមីងសំរាបឪពុកហើយនឹងម្ដាយរបស់អ្នកមីងគាត់ទាំង២នាក់មានឈ្មោះអ្វីដែលទៅអ្នកមីង???

ខៈ ចាសសំរាប់ម្ដាយរបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ម៉ី គុណ
ហើយសំរាប់ឪពុករបស់ខ្ញុំនឹងគឺគាត់មានឈ្មោះ កើត ផេង ចាស៕

កៈ
បាទហើយចឹងសំរាប់ឪពុកហើយនឹងម្តាយរបស់អ្នកមីងគាត់មានទីកន្លែងកំណើតនឹងទីកន្លែងណាដែលទៅអ្នកមីង???

ខៈ
ចាសសំរាប់ស្រុកកណើតរបស់ឪពុកហើយនឹងម្តាយរបស់ខ្ញុំនឹងគឺនៅស្រុកកោះនឹងដែលចឹងហាសចាសក៏ប៉ុនតែនឹងសំរាប់ខ្ញុំនឹងនៅពេលដែលខ្ញុំនឹងបានមានប្តីនឹងគឺខ្ញុំនឹងបានមករស់នៅកោះនឹងតែម្តងហាសចាសហើយតាមការពិតនឹងស្រុកកំណើតរបស់ខ្ញុំនឹងគឺនៅបាដាលនោះទេចាស៕

កៈ
បាទហើយចឹងទាំងឪពុកហើយនឹងម្តាយហើយនឹងកូនរបស់អ្នកមីងទាំងអស់នៅស្រុកនឹងទាំងអស់គ្នាមែនដែលទេអ្នកមីង???

ខៈ ចាសនិយាយទៅគឺនៅស្រុកនឹងទាំងអស់គ្នានឹងហាសចាស៕

កៈ
បាទហើយចឹងអរគុណាច្រើនមែនទែនអ្នកមីងហើយសំរាប់ថាសព្វថ្ងៃនឹងសំរាប់អ្នកមីងបានប្រកបមុខរបបអ្វីដែលទៅអ្នកមីង???

ខៈ ចាសសំរាប់សព្វថ្ងៃនឹងគឺខ្ញុំបានប្រកបមុខរបបត្បាញនឹងហាសចាស៕

កៈ
បាទហើយចឹងសំរាប់មុខរបបត្បាញនឹងអ្នកមីងត្បាញអស់រយះពេលប៉ុន្មានឆ្នាំហើយទៅអ្នកមីង???

ខៈ
ចាសសំរាប់ខ្ញុំគឺខ្ញុំបានត្បាញនឹងអស់រយះពេលចូលជាងមួយ១ឆ្នាំហើយហាសតាំងពីប្តីរបស់ខ្ញុំនឹងគឺគាត់បាននៅចឹងហាសចាស៕

កៈ
បាទហើយសំរាប់មុខរបបនឹងត្បាញនឹងមានភាពងាយស្រួលរឺក៏មានភាពពិបាក់រឺក៏យ៉ាងមិចដែលទៅអ្នកមីង???

ខៈ
ចាសនិយាយទៅគឺមានភាពពីបាក់ដែលចឹងហាសពីព្រោះអីនឹងនៅពេលដែលយើងបានធ្វើការកាត់អីនឹងគឺវាបានដាច់អំបោះដែលចឹងហាសចាសពីព្រោះអីនឹងគឺយើងនឹងវាចាស់ហើយចឹងហាសហើយសំរាប់គេដែលគេនៅក្មេងនឹងគឺមិនអីនោះទីចាសពីព្រោះអីនឹងសំរាប់យើ

ងចាស់ហើយហើយយ៉ាងទៀតនឹងភ្នែករបស់យើងនឹងក៏មើលមិនជាបានឃើញដែលចឹង ហាសចាសចឹងហើយវាមានភាពពិបាក់ដែលចាស។

កៈ
បាទហើយចឹងសំរាប់អ្នកមីងកាល់អ្នកមីងនៅក្មេងថាតើអ្នកមីងបានរៀនរឺក៏បានសិក្សាអីដែលរឺទេអ្នកមីង???

ខៈ
ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំបានរៀនសូត្រនឹងបានតិចតួចពីព្រោះអីនឹងសំរាប់ជីវភាពគ្រួសាររបស់ខ្ញុំនឹងគឺវាមិនជាសូវធូធារចឹងហាសចាសចឹងហើយគឺខ្ញុំបានរៀនបានតិចនោះទេចាស។

កៈ
បាទហើយចឹងសំរាប់អ្នកមីងរៀនបានតិចតួចនឹងថាតើអ្នកមីងរៀនបានថ្នាក់ទីប៉ុន្មានដែលទៅអ្នកមីង???

ខៈ ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំបានរៀនបានថ្នាក់ទី ៣ នោះទេចាស។

កៈ បាទហើយសំរាប់បានរៀនបានថ្នាក់ទី ៣
នឹងថាតើអ្នកមីងបានរៀននឹងនៅសាលាណាដែលទៅអ្នកមីង???

ខៈ ចាសសំរាប់ខ្ញុំនឹងបានរៀនថ្នាក់ទី ៣ នឹងគឺនៅសាលា បាដាល
ចាសនិយាយទៅគឺនៅវត្តបាដាលហាសចាសហើយនៅកន្លែងនឹងវាមានបាដាលខាងលើ ហើយនឹងបាដាលខាងក្រោមចាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំបានរៀននៅសាលារៀនវត្តបាដាលចាស។

កៈ
បាទហើយចឹងសំរាប់អ្នកមីងបានរៀននៅវត្តបាដាលលើរឺក៏បាដាលក្រោមដែលទអ្នកមីង???

ខៈ ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំបានរៀននៅសាលារៀនបាដាលលើចាស។

កៈ បាទហើយចឹងនៅពេលដែលអ្នកមីងបានរៀនបានថ្នាក់ទី ៣
នឹងថាតើសំរាប់អ្នកមីងគឺជាសិស្សពូកែរឺក៏ជាសិស្សមធ្យមរឺក៏ជាសិស្សខ្សោយរឺក៏យ៉ាងមិចដែលទៅអ្នកមីង???

ខៈ ចាសសំរាប់ខ្ញុំនឹងគឺជាសិស្សធម្មតានឹងហាសចាស។

កៈ
បាទហើយចឹងនៅពេលដែលអ្នកមីងបានរៀននឹងថាតើមុខវិជ្ជាអ្វីទៅដែលអ្នកមីងពូកែជាងគេដែលទៅអ្នកមីង???

ខ៖
ចាសប្រសិនជានិយាយទៅនៅពេលដែលខ្ញុំនឹងបានរៀននឹងគឺយើងសូវជាបានចង់ចាំហើយនឹងមិនបានរៀនចេះអីនឹងគេដែលចឹងហាសចាសពីព្រោះអីនឹងគឺថាយើងកំពុងតែរៀនផងហើយនឹងបានធ្វើការងារចឹងផងវាដូចថាមិនសូវជាស្ទាត់បានដូចកូនរបស់គេចឹងហាសចាសហើយណាមួយនឹងគឺខួលក្បាលរបស់យើងនឹងបានគិតថាយើងនឹងហើយនឹងគ្រួសាររបស់យើងនឹងវាអត់មានផងចឹងចាសចឹងហើយសំរាប់មុខវិជ្ជាអ្វីនឹងក៏យើងនឹងមិនសូវជាចងចាំអ្វីនឹងបានល្អដែលចឹងហាសចាស៕

ក៖
បាទហើយចឹងសំរាប់អ្នកមីងមិនបានដឹងថាអ្នកមីងបានរៀនពូកែខាងមុខវិជ្ជាអ្វីទេមែនដែលទេអ្នកមីងបាទហើយចឹងនៅពេលដែលអ្នកមីងបានទៅរៀននឹងថាតើអ្នកមីងមានមិត្តភក្តិណាដែលគាត់ជាមិត្តភក្តិស្និទស្នាលជាមួយនឹងអ្នកមីងដែលរឺទេអ្នកមីង???

ខ៖
ចាសនៅពេលដែលខ្ញុំនឹងបានរៀននឹងគឺខ្ញុំនឹងមានមិត្តភក្តិស្និតស្នាលដែលតាហើយគឺមានបងមួយដែលគាត់នឹងបាននៅជាប់ផ្ទះរបស់ខ្ញុំនឹងហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងមានមិត្តភក្តិស្និតស្នាលដែលគាត់បានរៀនជាមួយនឹងអ្នកមីងនឹងថាតើអ្នកមីងបានស្រឡាញហើយនឹងយកចិត្តទុក្ខដាក់ជាមួយនឹងគ្នាដែលរឺទេអ្នកមីង???

ខ៖
ចាសនៅពេលដែលខ្ញុំនឹងនៅរៀនហើយខ្ញុំមានមិត្តនឹងគឺខ្ញុំស្រឡាញគ្នាណាស់ដូចថានៅពេលដែលយើងនឹងមិនជាចេះអីនឹងហើយយើងនឹងទៅសួរគាត់ចឹងទៅគឺគេក៏បានប្រាប់យើងនឹងចឹងទៅ៕

ក៖
បាទហើយចឹអរគុណច្រើនចអ្នកមីងបាទហើយនៅពេលដែលអ្នកមីងរៀននឹងថាតើអ្នកមីងមានបានរៀនភាសាអ្វីទៀតដែលរឺទេក្រៅពីភាសាខ្មែរហាសអ្នកមីង???

ខ៖ ចាសគឺខ្ញុំរៀនតែភាសាខ្មែរនោះទេចាស៕

ក៖ បាទហើយចឹងអ្នកមីងបានចេះភាសាអ្វីក្រៅពីភាសាខ្មែរដែលរឺទេអ្នកមីង???

ខ៖ ចាសនិយាយទៅគឺខ្ញុំចេះតែភាសាខ្មែរនោះទេចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបឋមនៅសាលាបាដាលនឹងថាតើសំរាប់អ្នកមីងជិះអ្វីទៅរៀនដែលទៅអ្នកមីង???

ខ៖
ចាសនៅពេលដែលខ្ញុំទៅរៀននឹងគឺខ្ញុំដើរទៅរៀនចឹងហាសពីព្រោះអីនឹងគឺសាលារៀននឹងគឺនៅជិតដែលចឹងហាសចាស៕

ក៖
បាទហើយចឹងសំរាប់សាលារៀនរបស់អ្នកមីងមានចំងាយប៉ុន្មានគីឡូរដែលទៅអ្នកមីង???

ខ៖ ចាសនិយាយទៅគឺប្រហែលជា ១ គីឡូរអីនឹងហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលដើរទៅសាលារៀននឹងថាតើអ្នកមីងដើររយះពេលប៉ុន្មាននាទីទៅបានដើរទៅដល់សាលារៀនដែលទៅអ្នកមីង???

ខ៖ ចាសហើយប្រសិនជានិយាយទៅប្រហែលជាដើរអស់រយះពេល ២ នាទីអីនឹងហាសចាសនិយាយទៅគឺវាជិតដែលចឹងហាសចាស៕

ក៖ បាទហើយចឹងបានន័យថាសំរាប់ ១ គីឡូរនឹងអ្នកមីងដើរតែ ២ នាទីទេអ្នកមីង???

ខ៖
ចាសហើយនិយាយទៅគឺថាវានៅជិះដែលចឹងហាសចាសគឺវាមិនជាស្ងួរឆ្ងាយនោះទេចាស៕

ក៖ បាទហើយចឹងបានន័យថាអ្នកមីងដើរសោហារ ២ នាទីដើរបានមួយគីឡូរមែនដែលទេអ្នកមីងបាទហើយចឹងនៅពេលដែលដើរទៅសាលារៀននឹងថាតើអ្នកមីងដើរជាមួយនឹងមិត្តស្និតស្នាលជាមួយនឹងមិត្តភិក្តរឺក៏យ៉ាងក៏មិចដែលទៅអ្នកមីង???

ខ៖
ចាសនិយាយទៅគឺនៅពេលដែលខ្ញុំទៅសាលារៀននឹងគឺដើរជាមួយនឹងមិត្តភក្តិរបស់ខ្ញុំពេលខ្លះដែលចឹងហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានដើរចឹងបានន័យថាមិត្តភក្តិរបស់អ្នកមីងនៅខាងបាដាលហើយនៅសំរាប់អ្នកមីងមានដែលបានទៅលេងនឹងមិត្តភក្តិរបស់អ្នកមីងដែលរឺទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺខ្ញុំទៅដែលតាហើយនៅពេលដែលខ្ញុំនឹងទៅនឹងពីព្រោះអីនឹងគឺស្រុកកំណើតរបស់ពួកយើងនឹងនៅនឹងដែលចឹងហាសចាសហើយជួនកាល់នឹង១ឆ្នាំនឹងយើងនឹងបានទៅលេងបានមួយម្តងចឹងហាសចាសហើយនិយយាទៅគឺយើងមិនជាសូវបានទៅដែលហាសចាស៕

ក៖
បាទហើយចឹងខ្ញុំចង់សួរអ្នកមីងមួយទៀតថាតើនៅពេលដែលនៅក្នុងជំនាន់ពោលពតនឹងថាតើអ្នកមីងជួបនឹងបញ្ហាលំបាកអ្វីគេខ្លះដែលទៅអ្នកមីង???

ខ៖
ចាសនៅពេលដែលខ្ញុំនៅក្នុងជំនាន់ពោលពតនឹងគឺថាខ្ញុំនៅវ័យកុមារនោះទេចាសហើយនៅពេលដែលខ្ញុំនៅខាងក្រុមកុមារចឹងទៅហើយសំរាប់បងប្រុសរបស់ខ្ញុំនឹងគឺជាកងយុវជនហើយនិយាយទៅគឺមានកាលំបាកគឺមិនអត់នោះទេចាសដែលនៅក្នុងជំនាន់ពោលពតនឹងហាសចាសហើយសំរាប់ឪពុករបស់ខ្ញុំនឹងគ្រាន់តែចូលជំនាន់ពោលពតនឹងបានប៉ុន្មាននឹងគាត់ក៏បានស្លាប់ទៅគឺគាត់ស្លាប់ដោយសារជំងឺឈឺស្លាប់ចឹងទៅចាសនឹងសំរាប់ឪពុកបង្កើតរបស់ខ្ញុំនឹងហាសចាសហើយជំនាន់នឹងហើយមានដូចគេហើយគឺគេបានបញ្ចូលយើងទៅហើយថៃរក្សាហើយសំរាប់យើងនឹងដូចថាគឺគេបានគាត់សំរាប់ចឹងហាសហើយសំរាប់ជំនាន់នឹងគឺថាវាអត់មានឡានហើយគ្មានអ្វីនោះទេចាសគឺមានតែកងគឺគេបានចងនឹងអង្រឹងចឹងហាសចាសគឺចងមុខហើយនឹងក្រោយចឹងហាសចាសដល់ពេលដែលគាត់ឈឺចឹងទៅកូនរបស់ពូរបស់ខ្ញុំនឹងទៅយកនឹងគឺគេបានបានអោយយើងនឹងទៅយកនោះទេចាសដល់តែមានគេមានអ្នកជំនួយបានអោយយើងនឹងទៅយកនឹងបានគេអោយយើងនឹងទៅយកគាត់ហាសហើយនៅពេលដែលយើងទៅនឹងគឺគេបានអោយយើងនឹងសុំគេហើយប្រសិនជាយើងនឹងបានសុំទាន់ចឹងគឺយើងបានទៅហើយប្រសិនជាយើងនឹងមិនបានសុំគេទេគឺគេមិនបានអោយយើងទៅទេហើយប្រសិនជាយើងទៅយកចឹងទៅគឺគេបានមិនអោយយើងនឹងយកនោះទេចាសដល់ពេលហើយចឹងទៅសំរាប់ឪពុករបស់ខ្ញុំនឹងក៏គាត់នឹងបានស្លាប់នៅមន្ទីពេទ្យដែលនៅស្រុកកំណើតចឹងទៅចាស៕

ក៖ បាទហើយចឹងសំរាប់ឪពុករបស់អ្នកមីងគាត់ស្លាប់នៅក្នុងអាយុប៉ុន្មានឆ្នាំដែលអ្នកមីង???

ខ៖ ចាសសំរាប់ឪពុករបស់ខ្ញុំនឹងប្រសិនជានិយាយទៅគឺគាត់បានស្លាប់ប្រហែលជា ៥០ ឆ្នាំជាងអីនឹងហាសចាសហើយនិយាយទៅគឺនៅក្មេងដែលចឹងហាសចាសឪពុករបស់ខ្ញុំគឺគាត់នៅក្មេងដែលហាសចាស៕

ក៖ បាទហើយចឹងសំរាប់ឪពុករបស់អ្នកមីងគាត់បានស្លាប់ដោយសារអ្វីដែលទៅអ្នកមីង???

ខ៖
ចាសនៅពេលដែលគាត់បានស្លាប់នឹងគឺគាត់ស្លាប់ដោយសារឈឺចឹងហាសចាសសំរាប់ជំ

នាន់នឹងគឺថាដំបូងនឹងគឺគេបានចូលរួមធ្វើខាងសហាករហាសនឹងដំបូងដំបូងនឹងហាសចាស ហើយគាត់បានធ្វើការខាងសហាករនឹងគឺតាមស្រុកហាសចាសហើយនៅពេលដែលគាត់ធ្វើ ចឹងហើយចឹងទៅគឺគេបានអោយគាត់នឹងធ្វើការងារអោឈើនៅខាងបាដាលនឹងហើយនៅ ពេលដែលគាត់បានទៅដល់បាដាល់នឹងហើយចឹងទៅគឺវាមានគឺគេមានគេកាន់ចឹងទៅហើ យគាត់ចេះតែឈឺរហូតចឹងទៅចាសសំរាប់ជំនាន់នឹងហាសហើយនៅពេលដែលយើងនឹងមិ នត្រូវអីចឹងទៅគឺវាឈ្លបនឹងគឺវាចេះតែតាមដានយើងចឹងហាសចាសដូចថាយើងនឹងបានដា ក់ដាក់អីចឹងហាសចាសដល់ពេលចឹងទៅយើងនឹងក៏ពិបាក់ដែលចឹងហាសហើយនៅពេល ដែលគេបានយកឪពុករបស់ខ្ញុំនឹងហើយដល់ពេលចឹងទៅកូនរបស់គេនឹងគឺគេបានយកទៅ សំលាប់ចាសពីដំបូងនឹងនៅពេលដែលគាត់បានដើរប្ដីរបស់គាត់ចឹងទៅគឺគេបានដឹងយើង ហើយគេបាននិយាយថាយើងនឹងកុំទៅអីនៅទីកន្លែងនឹងមានគេមើលយើងហើយចឹងហា សចាសដល់ពេលចឹងហើយទៅថាអោយគាត់នឹងបានទៅផងចឹងហាសអោយគាត់បានដឹង ថាប្ដីរបស់គាត់នៅរស់រឺក៏ស្លាប់អោយគាត់នឹងបានអស់ចិត្តចឹងហាសចាសហើយអោយគាត់ នឹងបានដឹងថាគាត់ស្លាប់នៅកន្លែងណាចឹងហាសចាសហើយសំរាប់អ្នកខ្លះគេបានស្លាប់នឹង នៅជិះជិះនឹងហាសចាសដល់ពេលដែលប្ដីរបស់គាត់នឹងបានស្លាប់ចឹងទៅគឺគាត់មិនដឹងថា គេនឹងអោយប្ដីរបស់គាត់នឹងទៅដាក់នៅកន្លែងណានោះទេហើយគាត់នឹងក៏បានពរកូនរប ស់នឹងទៅតាមគេទាំងមិនបានដឹងថាគេយកទៅណាចឹងហាសហើយនៅពេលដែលប្ដីរបស់ គាត់បានស្លាប់ហើយគាត់បានឃើញអីចឹងទៅក៏គាត់នឹងបានដាក់ប្ដីរបស់គាត់ហើយគាត់ក៏ បានដើរចេញចឹងហើយនៅពេលដែលបានចេញហើយចឹងក៏យើងនឹងមិនបានដឹងទៀតដែ លថាគេនឹងយកទៅកប់នៅកន្លែងរឺក៏កន្លែងណារឺក៏យ៉ាងមិចដែលទៅគឺយើងនឹងមិនបានដឹ ងនោះទេដែលយើងនឹងបានដើរមកតាមផ្លូវមកស្រុកកំណើតរបស់យើងវិញនឹងហាសចាស ៕

ក៖
បាទហើយចឹងនៅក្នុងជំនាន់ពោលពតនឹងថាតើពួកពោលពតនឹងគេបានអោយអ្នកមីងធ្វើ ការងារអ្វីដែលលំបាក់អ្វីខ្លះដែលទៅអ្នកមីង???

ខ៖
ចាសប្រសិនជានិយាយទៅពីជំនាន់ពោលពតនឹងគឺពួកវានឹងបានអោយខ្ញុំនឹងបានទៅយាម ចាំសំណាមគេដែលគេបានស្ទុងស្រូវស្ទុងអីចឹងហាសគឺបានអោយយើងនឹងបានយាមហើ យចាប់ពីម៉ោង ៦ ល្ងាច
នឹងគឺពួកវានឹងបានអោយយើងនឹងបានដំរងជួរអោយហើយអោយយើងនឹងរង់ចាំស្រូវនឹង ហាសចាសហើយតាមវាល់ស្រែហើយនឹងបានដឹងទៅអូសហើយចឹងទៅហើយពួកវាបាន អោយយើងនឹងបានយាមហើយ ២០ ម៉ែត្រ មាន១នាក់ចឹងទៅហើយដល់ពេលដល់ម៉ោង ១១
អីនឹងបានពួកវាអោយយើងនឹងបានដំរង់ជួរនឹងសំរាប់ពួកម៉ាយដែលពួកវាបានអោយយើង នឹងបានធ្វើការងារនៅតាមមាត់បឹងនឹងហាសហើយពួកវានឹងមិនបានអោយយើងនឹងបានរ

ស់នៅជាមួយនឹងម្ដាយហើយនឹងឪពុករបស់យើងនឹងនោះទេចាសហើយពួកវានឹងបានអោយយើងនឹងបានស៊ីចុចបុកទំពារនឹងនៅទីកន្លែងនឹងទាំងអស់តែម្ដងហាសចាសបានហើយចឹងនៅពេលដែលដល់ពេលល្ងាចនឹងបានយើងទាំងអស់គ្នានឹងបានទៅហើយចឹងហាសហើយសំរាប់យប់ម៉ោង ១០ រឺក៏
១១អីនឹងបានយើងនឹងបានមកវិញចឹងហាសចាសពីព្រោះអីនឹងសំរាប់នោជំនាន់នឹងវាមានភាពលំបាក់ហើយសំរាប់នៅក្នុងជំនាន់នឹងហាសដែលជាជំននាំពោលពតនឹងហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលគេមិនបានអោយអ្នកមីងនឹងបានរស់នៅជាមួយនឹងឪពុកកហើយនឹងម្ដាយរបស់អ្នកមីងនឹងថាតើអ្នកមីងមានបាននឹកឪពុកហើយនឹងម្ដាយរបស់អ្នកមីងដែលរឺទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺខ្ញុំនឹងឪពុកហើយនឹងម្ដាយរបស់ខ្ញុំនឹងហាសដូចថានឹកឪពុកហើយហាម្ដាយរបស់ខ្ញុំដែលខ្ញុំបានដេកជាមួយឪពុកហើយនឹងម្ដាយរបស់ខ្ញុំចឹងហាសចាសតែសំរាប់នៅក្នុងជំនាន់នឹងដូចថាយើងបានដឹងខ្លះចឹងហើយយើងនឹងមិនបានដឹងខ្លះចឹងហាសចាសពីព្រោះអីនឹងគឺគេបានអោយយើងនឹងបានទៅធ្វើជាកងកុមារអីចឹងហាសចាសហើយសំរាប់បងបងរបស់ខ្ញុំនឹងដូចថាគាត់នឹងធំជាងខ្ញុំចឹងគឺគេបានអោយគាត់នឹងបានទៅធ្វើជាងកងចល័តធំចឹងហាសចាសហើយសំរាប់ខ្ញុំនឹងនៅក្មេងនឹងគឺគេបានអោយខ្ញុំនឹងនៅខាងកងកុមារចាសហើយនៅពេលដែលគេបានច្រូតស្រូវអីនឹងគឺគេបានអោយក្មេងនឹងបានទៅលីសែនចឹងហាសចាសហើយនឹងគេបានអោយយើងនឹងបានចង់កាក្ដាបអីចឹងទៅចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបាននឹកឪពុកហើយនឹងម្ដាយរបស់អ្នកមីងចឹងថាតើអ្នកមីងធ្វើយ៉ាងមិចដែលទៅបានអ្នកមីងអាចជួបនឹងឪពុកហើយនឹងម្ដាយរបស់អ្នកមីងថាតើអ្នកមីងធ្វើយ៉ាងមិចដែលទៅ???

ខ៖
ចាសប្រសិនជានិយាយទៅនៅពេលថ្ងៃអីនឹងគឺយើងនឹងអាចសុំប្រធានរបស់យើងនឹងបានមកបានហើយដល់ពេលល្ងាចម៉ោង៣អីនឹងគឺយើងនឹងទៅវិញចឹងទៅចាសនិយាយទៅគឺឆ្ងាយដែលនឹងហាសចាសពីព្រោះអីនឹងនៅពេលដែលយើងនឹងទៅនឹងគឺយើងទៅពីព្រឹកព្រលឹមហើយដល់ពេលដល់ម៉ោង៣នឹងយើងនឹងទៅវិញហើយយើងនឹងត្រូវចាំកន្លែងដ៏ដែលរបស់យើងចឹងហាសាចាសដូចថាយើងនៅចាំកណ្ដុលហើយនឹងដុតភ្លើងហើយនឹងចាំកណ្ដុលចឹងហាសពីប្រោះអីនឹងយើងខ្លាចវានឹងស៊ីស្រូវរបស់យើងចឹងហាសចាសហើយនឹងធ្វើអោយកណ្ដុលនឹងកុំអោយកណ្ដុលនឹងបានមកជិតស្រូវរបស់យើងចឹងហាសចាសហើយប្រសិនជាយើងនឹងមិនទៅទេគឺគេនឹងមិនបានអោយបបរនឹងសំរាប់ហូបនោះទេចាស៕

ក៖
បាទហើយចឹងនៅពេលដែលគបានអោយអ្នកមីងទៅចាំយាមកណ្ដុលកុំអោយកណ្ដុលនឹងមកស៊ីស្រូវរបស់យើងចឹងថាតើសំរាប់អ្នកមីងមានភាពលំបាក់ដែលរឺតេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺវាមានភាពលំបាក់ដែលចឹងហាសពីព្រោះអីនឹងគឺវាជាពេលយប់ចឹងហាសពីព្រោះអីនឹងគឺថាសំរាប់
២០ម៉ែត្រមានមនុស្សម្នាក់ចឹងហាសចាសហើយនៅពេលដែលយើងនៅយាមចឹងទៅគឺយើងនឹងងួយដេកអីខ្លះចឹងទៅហើយដល់ពេលដែលដល់ម៉ោង១១យប់អីនឹងបានអោយយើងនឹងបានដំរង់ជួលនឹងបានមកវិញមកចឹងហាសចាសនិយាយទៅគឺវេទនាដែលនឹងហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលគេបានអោយអ្នកមីងនឹងបានយាមទាំងយប់ចឹងថាតើអ្នកមីងមានបានកើតជំងឺឈឺអ្វីដែលរឺទេដែលបណ្ដាលមកពីមូសកាំអីដែលរឺទេអ្នកមីង???

ខ៖
ចាសនិយាយទៅវាមានមូសកាំដែលចឹងហាសក៏ប៉ុនតែនឹងនិយាយទៅវាមិនសូវដូចមកជំនាន់លូវនឹងទេចាសវាដូចអត់ឈឺដែលចឹងហាសហើយប្រសិនជានិយាយទៅគឺមិនសូវជាឈឺហាសហើយសំរាប់មូសកាំកាំហើយក៏ប៉ុនតែនឹងគឺវាមិនសូវជាឈឺនោះទេចាសហើយក៏មិនសូវជាមានជំងឺនឹងឈឺអ្វីដែលចឹងហាសចាស៕

ក៖
បាទហើយចឹងនៅក្នុងជំនាន់នឹងសំរាប់គេបានអោយអ្នកមីងទៅយាមកណ្ដុលនឹងអ្នកមីងមិនសូវឈឺអ្វីនោះទេមែនដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅមិនសូវជាឈឺនោះទេចាសសំរាប់ជំនាន់នឹងគឺមិនសូវជាអ្វីនោះទេចាស៕

ក៖
បាទហើយចឹងសំរាប់អ្នកមីងមានដឹងដែលទេសំរាប់នៅក្នុងជំនាន់ណាដែលរឺទេដែលគេបានជួយរំដោះប្រជាជនខ្មែររបស់យើនឹងនៅក្នុងឆ្នាំណាដែលរឺទេអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំមិនបានចាំនៅក្នុងជំនាន់ណាជំនាន់ណានោះទេចាសគ្រាន់តែខ្ញុំនឹងបានដឹងតែប៉ុននឹងចឹងហាសចាសពីព្រោះអីនឹងសំរាប់ជំនាន់នឹងគឺយើងនឹងនៅក្មេងនោះទេចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានបែកពីជំនាន់ពោលពតនឹងថាតើអ្នកមីងបានស់នៅទីកន្លែងណាដែលទៅអ្នកមីង???
ខ៖
ចាសសំរាប់ខ្ញុំនៅពេលដែលខ្ញុំនឹងបានបែកពីជំនាន់ពោលពតនឹងគឺខ្ញុំបានរស់នៅទីកន្លែងនឹងតែម្តងហាសចាស៕

ក៖ បាទហើយសំរាប់រស់នៅភូមិអ្វីហើយនឹងស្រុកអ្វីដែលទៅអ្នកមីង???

ខ៖ ចាសគឺខ្ញុំនឹងបានរស់នៅភូមិបាដាល់ ស្រុកខ្សោចកណ្តាល ខេត្តកណ្តាល ចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានបែកពីជំនាន់ពោលពតនឹងសំរាប់អ្នកមីងរត់មកជាមួយនឹងក្រុមគ្រួសាររបស់អ្នកមីងរឺក៏អ្នកមីងបានរត់មកជាមួយនឹងអ្នកគេដែលទៅអ្នកមីង???
ខ៖
ចាសហើយប្រសិនជានិយាយទៅគឺថានៅក្នុងជំនាន់ពោលពតនឹងគឺគេមិនបានជំលាស់យើងនឹងទៅណានោះទេចាសនឹងសំរាប់ជំនាន់ពោលពតនឹងហាសចាសគឺគេមិនបានជំលាស់យើងនោះទេគ្រាន់តែថាគេបានប្រមូលសិស្សសាលាដែលនៅក្មេងក្មេងហាសចាសហើយនៅពេលដែលគេបានយកមកហើយចឹងគឺគេអោយយកមកមើលកណ្តុលហើយនឹងធ្វើជាពេងហើយនឹងបានដេកអីនឹងអីនៅនឹងចឹងហាសចាសនឹងហើយគឺគេមិនបានជំលាស់យើងនឹងទៅណានោះទេដល់ពេលចឹងទៅគឺគេបានអោយយើងនឹងបានមកតាមផ្ទះចឹងមកហើយយើងនឹងបានជួបជុំជាមួយនឹងឪពុកហើយនឹងម្តាយរបស់យើងចឹងហាសគឺគេមិនបានអោយយើងនឹងបានបែកទៅណានោះទេចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានរត់ពីជំនាន់ពោលពតមកហើយចឹងគឺជាមួយនឹងក្រុមគ្រួសាររបស់អ្នកមីងហើយចឹងហើយអ្នកមីងមែនដែលទេអ្នកមីងបាទហើយចឹងសំរាប់អ្នកមីងបានរត់មករស់នៅស្រុកកំណើតនៅទីកន្លែងនេះវិញតែម្តងមែនដែលទេអ្នកមីងបាទហើយចឹងខ្ញុំចង់សួរអ្នកមីងថានៅពេលដែលអ្នកមីងនៅក្នុងជំនាន់ពោលពតហើយនឹងនៅពេលបច្ចុប្បន្ននេះហើយប្រសិនជាប្រៀបធៀបថាតើវាមានភាពខុសគ្នាយ៉ាងដូចម្តេចដែលទៅអ្នកមីង???

ខ៖
ចាសនិយាយទៅប្រសិនជាយើងបានប្រៀបធៀបទៅនឹងគឺវាខុសគ្នាត្រង់ថានៅក្នុងជំនាន់ពោលពតនឹងមានការលំបាក់នឹងស៊ីចុចបុកទំពារនឹងក៏វាមិនបានគ្រាប់គ្រាន់ដែលចឹងហាសចាសហើយក៏វាមិនមានសេរីភាពអីដែលចឹងហាសចាសហើយសំរាប់មកដល់ពេលលូវនេះវិញគឺថានៅពេលដែលយើងបានធ្វើការងាររបស់យើងនឹងយើងបានលុយរបស់យើងនឹងហា

សហើយនៅពេលដែលយើងមកសូវជាស្រួលខ្លួននឹងគឺយើងអាចសំរាក់បានចឹងទៅចាស ហើយសំរាប់ជំនាន់ពោលពតនឹងគឺគ្មាននោះទេធ្វើការងារទាំងឈឺទាំងជាចាស៕

ក៖
បាទហើយចឹងសំរាប់នៅក្នុងជំនាន់ពោលពតនឹងគឺវាមានភាពពីបាក់ជាងមែនដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺវាមានភាពពិបាក់ជាពីព្រោះអីនឹងទាំងការហូបចុចហើយនឹងការរស់នៅនឹងគឺមានភាពពិបាក់ជាងហាសចាសហើយមិនដូចលូវនេះនោទេហើយសំរាប់លូវនឹងនេះដូចវាថាមានភាពងាយស្រួលជាងវាដូចថាយើងបានធ្វើការងាររបស់យើងចឹងហាសហើយនៅពេលដែលយើងនឹងឈឺថ្ងៃណាគឺយើងនឹងបានសំរាក់ដោយខ្លួនរបស់យើងចឹងទៅហាសហើយសំរាប់ជំនាន់ពោលពតនឹងគឺគ្មាននោះទេចាសគឺយើងនឹងទៅទាំងឈឺទាំងជាហើយហាយប្រសិនជាយើងនឹងមិនបានទៅគឺគេមិនបានអោយយើងនឹងបានហូបបបរនោះទេចាសហើយនឹងមិនបានហូបបាយនោះទេចាសហើយប្រសិនជាយើងគិតទៅសំរាប់អង្ករមួយគីឡូវាគឺវាធ្វើបានបបរនឹងបានមួយខ្ទះហាសចាស៕

ក៖
បាតហើយចឹងសំរាប់អាចចែកចាយបានដែលទេថាមកដល់ពេលបច្ចុប្បន្ននេះសំរាប់អ្នកមីងមានភាពសប្បាយអ្វីដែលខ្លះនៅពេលដែលអ្នកមីងបានបែកពីជំនាន់ពោលពតហើយចឹងហាសអ្នកមីង???

ខ៖
ចាសនិយាយទៅគឺសប្បាយត្រង់ថាយើងនឹងបានមកជួបជុំជាមួយនឹងក្រុមគ្រួសាររបស់យើងចឹងហាសចាសហើយដូចថានៅពេលដែលយើងនឹងបានទៅណាមកណាចឹងវាមានភាពងាយស្រួលអីចឹងហាសចាសគឺវាមិនដូចជាជំនាន់ពោលពតនោះទេចាសហើយសំរាប់ពោលពតនឹងគឺពិបាក់ខ្លាំងណាស់ដូចថាយើងធ្វើអ្វីចឹងក៏គេមានឈ្លបរបស់គេនឹងបានមកតានដានយើងចឹងហាសហើយសំរាប់មកដល់លូវនឹងវាមានភាពងាយស្រួលហើយយើងនឹងចង់ទៅណាមកណានឹងវាដូចថាវាល្អចឹងហាសចាសគ្រាន់តែថានៅពេលដែលយើងនឹងទៅណាមកណាអីចឹងគឺវាមានសុវត្ថិភាពតាមផ្លូវចឹងហាសចាស៕

ក៖
បាទហើយចឹងសំរាប់អ្នកមីងមានបទពិសោធន៍អ្វីដែលសប្បាយទៀតដែលរឺទេក៏ដូចជាភាពសប្បាយរីករាយជាមួយនឹងក្រុមគ្រួសាររបស់អ្នកមីងចឹងហាសថាតើអ្នកមីងមានអ្វីដែលសប្បាយទៀតដែលរឺទេអ្នកមីង???

ខ៖
ចាសសំរាប់អ្វីដែលសប្បាយជាមួយនឹងក្រុមគ្រួសារជាមួយនឹងក្រុមគ្រួសារនឹងដូចថានៅពេ

លដែលថ្ងៃសៅរ៍ហើយនឹងថ្ងៃអាទិត្យអីចឹងទៅកូនចៅរបស់ខ្ញុំនឹងបានបបួលបានដើរលេងចឹងទៅដូចថាសប្បាយរីករាយជាមួយនឹងក្រុមគ្រួសារចឹងទៅចាសមានអីចឹងទៅហើយយើងនឹងបានសប្បាយហាសហើយគ្រាន់តែថាយើងនឹងសប្បាយនឹងគឺយើងនឹងមិនបានសប្បាយនឹងរាល់ថ្ងៃនោះទេចាស៕

ក៖

បាទហើយចឹងខ្ញុំចង់សួរទៅកាន់អ្នកមីងមួយទៀតថាតើអ្នកមីងប្រកបមុខរបបជំត្បាញនេះអស់រយះពេល១០ឆ្នាំហើយមែនដែលអ្នកមីងហើយសំរាប់អ្នកមីងមានបានដែលគិតទេថាការងារប្រកបមុខរបបជំត្បាញនេះប៉ុន្មានឆ្នាំទៀតបានអ្នកមីងសំរាក់ដែលទៅអ្នកមីង???

ខ៖

ចាសនិយាយទៅគឺខ្ញុំមិនទាន់ដឹងនោះទេចាសពីព្រោះអីនឹងគឺខ្ញុំមិនដឹងថាខ្លួនឯងនឹងបានធ្វើការងារនឹងបានប៉ុនណាទៀតនឹងគឺខ្ញុំមិនដឹងទេចាសហើយសំខាន់សំរាប់កំលាំងរបស់យើងនឹងចេះតែទៅហើយចឹងហាសចាសដូចថានៅពេលដែលយើងចប់ត្រឹមណាគឺយើងនឹងចប់ត្រឹមនឹងតែម្តងហាសចាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំមិនទាន់ហ៊ានស្មន់ម្មត់ថាបានប៉ុនណានោះទេចាសហើយប្រសិនជាបានប៉ុនណាគឺប៉ុននឹងហើយចឹងហាសចាស៕

ក៖

បាទហើយចឹងខ្ញុំចង់សួរអ្នកមីងមួយទៀតចឹងនៅពេលដែលអ្នកមីងបានជួយជំត្បាញរឺក៏ធ្វើការងារនឹងថាតើអ្នកណាដែលគាត់ជាអ្នកផ្គត់ផ្គង់សំរាប់ក្រុមគ្រួសាររបស់អ្នកមីងដែលទៅអ្នកមីង???

ខ៖

ចាសនៅពេលដែលខ្ញុំបានប្រកបមុខរបបនឹងគឺកូនស្រីរបស់ខ្ញុំនឹងគឺគាត់ជាអ្នកផ្គត់ផ្គង់សំរាប់ក្រុមគ្រួសាររបស់ខ្ញុំនឹងហាសចាស៕

ក៖

បាទហើយចឹងបានន័យថាសំរាប់កូនស្រីរបស់អ្នកមីងគាត់ជាអ្នកផ្គត់ផ្គង់សំរាប់ក្រុមគ្រួសាររបស់អ្នកមីងមែនដែលទេអ្នកមីង???

ខ៖

ចាសគឺកូនរបស់ខ្ញុំគឺជាផ្គត់ផ្គង់ចឹងហាសនិយាយទៅដូចថាកូនរបស់ខ្ញុំនឹងគឺវាចេះហើយសំរាប់ខ្ញុំនឹងគឺខ្ញុំមិនដែលបានចេះនោះទេចាសពីព្រោះអីនឹងនៅពេលដែលខ្ញុំនឹងបានឈឺហើយគាត់បានស្លាប់នឹងចឹងនៅក្នុងជំនាន់នឹងក៏ខ្ញុំនឹងបានកូនបង្រៀនហើយនៅពេលដែលខ្ញុំនឹងបានជំត្បាញចេះចឹងទៅហើយកូនរបស់ខ្ញុំនឹងក៏បានបង្រៀនជំត្បាញសូត្រអោយចឹងទៅហាចាសពីព្រោះអីនឹងគឺខ្ញុំមិនដែលបានជំត្បាញចឹងហាសចាសក៏ប៉ុនតែនឹងសំរាប់ការងារជំត្បាញនឹងគឺខ្ញុំធ្វើវានឹងអស់រយះពេលនឹងបាន ១០ ឆ្នាំហើយចឹងចាស៕

ក៖
បាទហើយចឹងសំណួរចុងក្រោយដែលខ្ញុំចង់សួរទៅកាន់អ្នកមីងថាតើអ្នកមីងមានអ្វីផ្ដែលផ្ដាំទៅកាន់កូនចៅរបស់អ្នកមីងដែលរឺទេនៅពេលដែលគាត់បានលឺសំលេងរបស់អ្នកមីងហើយថាតើអ្នកមីងមានអ្វីផ្ដែលផ្ដាំទៅកាន់គាត់ដើម្បីអោយគាត់នឹងបានខំប្រឹងប្រែបន្ថែមដើម្បីអោយជីវភាពនៅក្នុងក្រុមគ្រួសាររបស់អ្នកមីងមានភាពល្អប្រសើរហើយនឹងខំប្រឹងប្រែគោរពឪពុកហើយនឹងម្ដាយថាតើអ្នកមីងមានផ្ដែលផ្ដាំទៅកាន់គាត់ដែលរឺទេអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំចង់ផ្ដែលផ្ដាំទៅកាន់កូនកូនរបស់ខ្ញុំនឹងហាសចាសសូមអោយប្រឹងប្រែរកស៊ីនឹងមានបានទាំងក្រុមគ្រួសារហើយនឹងមានភាពសប្បាយចិត្តហាសហើយបានរកកូនចេះធូរចាស៕

ក៖ បាទហើយសំរាប់អ្នកមីងមានអ្វីចង់ផ្ដែលផ្ដាំទៀតដែលរឺទេអ្នកមីង???

ខ៖ ចាសនិយាយទៅគឺអត់មានទៀតនោះទេចាស៕

ក៖
បាទអត់មានទេអ្នកមីងហេហេហេហេបាទហើយចឹងសំរាប់ថ្ងៃនឹងគឺខ្ញុំសប្បាយចិត្តមែនទែនអ្នកមីងដែលអ្នកមីងបានផ្ដល់ឪកាសអោយខ្ញុំដើម្បីបានសំភាសន៍អ្នកមីងអំពីជាជីវប្រវត្តិរបស់អ្នកមីងដែលនៅក្នុងជំនាន់ពោលពតចឹងហាសហើយអរគុណច្រើនសំរាប់ពេលដល់មានតំម្លៃរបស់អ្នកមីងដែលបានជួយប្រាប់ពីជីវិតរបស់អ្នកមីងដែលនៅក្នុងជំនាន់ពោលពតផងហើយនឹងបច្ចុប្បន្នភាពផងថាសំរាប់២នឹងវាមានភាពខុសគ្នាយ៉ាងដូចម្ដេចហើយចឹងសំរាប់ថ្ងៃនឹងគឺខ្ញុំនឹងសប្បាយចិត្តមែនទែនហើយសំរាប់ថ្ងៃនឹងគឺខ្ញុំអត់អ្វីច្រើនទៀតទេសំរាប់អ្នកមីងបាទហើយចឹងសំរាប់អ្នកមីងចង់ផ្ដែលផ្ដាំទៅកាន់កូនរបស់អ្នកមីងបន្តិចទៀតដែលរឺទេអ្នកមីង???

ខ៖
ចាសខ្ញុំសូមផ្ដែលផ្ដាំទៅកាន់កូនចៅរបស់ខ្ញុំនឹងទាំងអស់ដែលខ្ញុំនឹងបានហៅនឹងហាសទាំង
៨
នាក់នឹងសូមអោយកូនរកស៊ីមានបានហើយនឹងបានជួបជុំនឹងក្រុមគ្រួសារហើយនឹងមានភាពរីកចំរើនហើយសំរាប់ម្ដាយមានភាពសប្បាយចិត្តចំពោះកូនចៅហើយដែលបានលឺម្ដាយបាននិយាយចាសហើយសូមអោយកូននឹងបានសុខសប្បាយសុខទាំងអស់គ្នាចាស៕

ក៖
បាទហើយចឹងអរគុណច្រើនអ្នកមីងសំរាប់ការផ្ដែលផ្ដាំទៅកាន់កូនចៅរបស់អ្នកមីងបាទហើយចឹងសំរាប់ថ្ងៃនឹងគឺខ្ញុំមានតែប៉ុននឹងអ្នកមីងហេហេហេហេបាទហើយចឹងអរគុណច្រើនអ្នកមីងហើយអរគុនជំរាបលាអ្នកមីង៕៕៕